# អកុសលកម្មបថ

គន្លងវីផ្លូវនៃអំពើជាអកុសល ហៅថា អកុសលកម្មបថ មាន១០យ៉ាងគឺ កាយកម្មអំពើដែលសំរេចដោយកាយមាន៣ យ៉ាង វចីកម្ម អំពើដែលសំរេចដោយវាចាមាន៤យ៉ាង មនោកម្ម អំពើដែលសំរេចដោយចិត្តមាន៣ យ៉ាង រួមត្រូវជា១០យ៉ាង

កាយកម្មមាន ៣យ៉ាង

- ១ -បាណាតិបាតោ កិរិយាសំលាប់សត្វដោយកាយរបស់ខ្លួន រឺប្រើគេអោយសំលាប់ដោយវាចារ។
- ២ -អទិន្នាទានំ កិរិយាលាក់ឆក់លួច ដណ្តើមទ្រព្យគេ ដោយកាយរបស់ខ្លួនរឺប្រើអោយគេលួចលាក់ឆក់ដណ្តើមដោយវាចា។
- ៣ - កាមេសុ មិច្ឆាចារា កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេ ថុនសេវនៈនិងស្ត្រី រឺបុរសដែលមានគេហួងហែងរក្សា។

៤យ៉ាងវចីកម្ម

- ១ -មុសាវាទោ កិរិយាពោលនូវពាក្យកុហក
- ២ -បិសុណាវាចា កិរិយាពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ
- ៣ - ផរុសវាចា កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម។
- ៤ - សម្ផប្បលាបោ កិរិយាពោលនូវពាក្យរោយរាយអិតប្រយោជន៍។

មនោកម្ម៣យ៉ាង

- ១ -អភិជ្ឈា ចិត្តសំលឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹង អោយបានជារបស់ខ្លួន។
- ២ - ព្យាបាទោ ចិត្តចងគំនំគុំគួនប៉ងនឹងអោយអ្នកដទៃដល់នូវសេចក្តីវិនាស
- ៣ - មិច្ឆាទិដ្ឋិ គំនិតយល់ខុស ហើយប្រកាន់ឡើងថាត្រូវ។

អង្គនៃអកុសលកម្មបថ

អង្គនៃ បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ និងមុសាវាទ មានដូចពោលក្នុង និច្ចសីលខាងដើម
នោះហើយ

បិសុណាវាចា មានអង្គ៤

- ១ -ភិន្ទិតព្វោ បរោ អ្នកដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក។
- ២ -ភេទនបុរេក្ខារតា គិតនឹងញុះញង់បំបែកអ្នកដទៃ។
- ៣ -តជ្ជោ វាយាមោ ព្យាយាមនឹងញុះញង់បំបែកអ្នកដទៃនោះ
- ៤ - តស្សសទត្ថវិជាននំ ញ៉ាំងអ្នកនោះអោយដឹងច្បាស់នូវដំណើរ ដែលខ្លួន ញុះញង់នោះ។

ផរុសវាចាមានអង្គ៣

- ១ -អក្កោសិតព្វោ បរោ អ្នកដទៃមានរូបគឺខ្លួនគប្បីជេរប្រទេច។
- ២ - កុប្បិតចិត្តំ ចិត្តខឹងរន្ធត់។
- ៣ - អក្កោសនា បានជេរប្រទេចគេ។

សម្ផប្បលាបៈ មានអង្គ២

- ១ - ភារតយុទ្ធសិតាហរណាទិនិរត្ថកថា ពាក្យអិតប្រយោជន៍ មានរឿងចំបាំង នៃមហាភាតរ និងរឿងរាពណ៍លួចនាំនាងសិតាទៅតាមជាដើម។ ។
- ២ - តថារូបីកថាកថនំ បានពោលនូវពាក្យអិតប្រយោជន៍ មានសភាពដូច្នោះ។

អភិជ្ឈាមានអង្គ២

- ១ - បរភណ្ឌំ ទ្រព្យជារបស់អ្នកទៃ។
- ២ - អត្តនោ បរិណាមនំ គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះអោយបានមកជាទ្រព្យរប

ស់ខ្លួន ដោយកលអុបាយផ្សេងៗ។

ព្យាបាទៈ មានអង្គ២

- ១ -បរសត្តោ អ្នកដទៃក្រៅពីខ្លួន។
- ២ តស្ស តំ តំ វនាសចិន្តា គិតគំគួនប្រុងនឹងអោយអ្នកនោះដល់នូវសេចក្តីវិនាសដោយហេតុនោះៗ។

មិច្ឆាទិដ្ឋិ មានអង្គ២

- ១ - វត្ថុនោ ច គហិតាការវិបរិតតា ចិត្តប្រែព្រួលដោយអាការខុសអំពីព្រះរតនត្រៃជាដើម
- ២ - យថា ច នំ គណ្ហាតិ តថាភាវេន តស្សូបដ្ឋានំ គំនិតដែលយល់ខុសនោះឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តីខុសនោះថាជាត្រូវវិញ។

អកុសលកម្មបថ ១០ប្រការ ដូចបានពោលមកហើយនេះ ទោះត្រង់បទណាក្តី បើលុះព្រមដោយអង្គនោះៗ ទើបត្រូវទោសដល់អ្នកប្រព្រឹត្តខុស អ្នកនោះនឹងបាននូវសេចក្តីទុក្ខ សេចក្តីវិនាសក្នុងលោកនេះនិងបរលោកនាយ បើទុកជាមិនទាន់អោយផល អោយឃើញច្បាស់ក្នុងលោកនេះលុះដល់ទៅក្នុងបរលោកនាយ ក៏គង់នឹងអោយផលដល់អ្នកនោះពុំខានឡើយ បើមិនទាន់ព្រមដោយអង្គនោះៗ គឺថាបើនៅខ្វះអង្គណាមួយនោះ ក៏មិនទាន់បានឈ្មោះថាមានទោសក្នុងអកុសលកម្មបថដល់អ្នកដែលប្រព្រឹត្តខុសនៅឡើយ។

## អកុសលកម្មបថ១០ប្រការ ព្រមទាំងអង្គ ចប់ដោយសង្ខេបតែប៉ុណ្ណេះ

### កុសលកម្មបថ

គន្លងរឺផ្លូវនៃអំពើជាកុសល ហៅថា កុសលកម្មបថ កុសលកម្មបថមាន យ៉ាងគឺ កាយកម្ម អំពើដែលសំរេចដោយកាយមាន ៣យ៉ាង, វចីកម្ម អំពើដែលសំរេចដោយវាចាមាន៤យ៉ាង មនោកម្ម អំពើដែលសំរេចដោយចិត្តមាន៣ យ៉ាង រូមត្រូវជា១០យ៉ាង។

កាយកម្មមាន ៣យ៉ាង

- ១ -បាណាតិបាតា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតអោយធ្លាក់ចុះកន្លងគឺសំលាប់សត្វ។
- ២ - អទិន្នាទានា វេរមណីចេតនាជាហេតុវៀរចាកកិរិយា កាន់យកនូវវត្ថុដែលគេមិនបានអោយដោយកាយ រឺវាចា។
- ៣ -កាមេសុ មិច្ឆាចារា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្ត ខុសក្នុងកាមទាំងឡាយ។

វចីកម្ម មាន៤យ៉ាង

- ១ -មុសាវាទា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យ កុហក។
- ២ -បិសុណាយ វាចាយ វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោល នូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ។
- ៣ -ផរុសាយ វាចាយ  វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោល នូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម។
- ៤ -សម្ផប្បលាបា វេរមណីចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយអិតប្រយោជន៍។

មនោកម្ម៣យ៉ាង

- ១ -អនភិជ្ឈា មិនមានចិត្តសំលឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយ គិតបំរុងនឹងអោយបានជារបស់ខ្លួន។
- ២ -អព្យាបាទោ មិនមានចិត្តចងគំនំគុំគួនប៉ងនឹងអោយអ្នកដទៃដល់នូវ សេចក្តីវិនាស
- ៣ -សម្មាទិដ្ឋិ គំនិតយល់ឃើញត្រូវពិត ដោយប្រកាន់ឡើងថាជាត្រូវមែន។

អ្នកអែណាបានប្រព្រឹត្តត្រូវតាមកុសលកម្មបថទាំង១០ប្រការ ដូចបានពោលមកហើយនេះអ្នកនោះនឹង បានសេចក្តីសុខ សេចក្តីចំរើនក្នុងលោកទាំងពីរ គឺក្នុងលោកនេះ និងបរលោកនាយជាប្រាកដ។

កុសលកម្មបថ១០ប្រការ ចប់ដោយសង្ខេបតែប៉ុណ្ណោះ